# មជ្ឈមណ្ឌលឯកសារកម្ពុជា

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្លេងយុត្តិធម៌៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## វគ្គទី៦

## ប្រធានបទ៖ ការអត់ឃ្លាន និងឧក្រិដ្ឋកម្មសង្គ្រាម


*ដោយ ៖ វ៉េនឌល ឌឹហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ ៖ ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែសីហា ឆ្នាំ២០១៣*


*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៦ ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់យើងខ្ញុំ ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រ និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិ-ធម៌ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។ ចំពោះប្រិយមិត្តអ្នកស្តាប់ដែលរស់នៅរាជធានីភ្នំពេញ និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា* FM105.75 MHz *រាជធានីភ្នំពេញ វេលាម៉ោង ១រសៀល និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈ វិទ្យុខេត្តកំពត* FM93.25 *វេលាម៉ោង៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈ វិទ្យុខេត្តព្រះវិហារ* FM99 *វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង* FM103.25 *វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។*

ការផ្សាយក្នុងវគ្គទី៦នេះ ផ្តោតសំខាន់ទៅលើច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមផ្សេងៗ និងស្វែងយល់ថាតើច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមអាចអនុវត្តចំពោះការអត់ឃ្លាន ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀតដែរឬទេ ។ នៅក្នុងវគ្គនេះ យើងនឹងធ្វើការបកស្រាយពី ពាក្យឧក្រិដ្ឋកម្មសង្គ្រាម ដោយលើកយកឧទាហរណ៍នៃឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួន ដែលអាចជាប់ទាក់ទងទៅនឹងលក្ខខណ្ឌនៃការអត់ឃ្លាន មកពិភាក្សា ។

## សេចក្តីផ្តើមៈ តើឧក្រិដ្ឋកម្មសង្គ្រាមជាអ្វី?

ឧក្រិដ្ឋកម្មសង្គ្រាម គឺជាការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់សង្គ្រាម ដែលមានឈ្មោះជាផ្លូវការថា "ច្បាប់មនុស្សធម៌អន្តរជាតិ" ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីកាត់បន្ថយការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិស៊ីវិល និងប្រជាជនដែលមិនបានចូលរួមធ្វើសង្គ្រាម ក្នុងអំឡុងពេលដែលមានសង្គ្រាម ។ លុះត្រាតែ មានតែការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌តែប៉ុណ្ណោះ ទើបអាចចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាមបាន ។ ច្បាប់មនុស្សធម៌ គឺជាផ្នែកចាស់មួយនៃច្បាប់អន្តរជាតិ និងច្បាប់សង្គ្រាមថ្មី ដែលបានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ កាលពីដើមទសវត្ស ឆ្នាំ ១៩០០ ហើយអាចមុននឹងទៅទៀត ។

ដូចគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីកាត់ទោសជនល្មើស បន្ទាប់ពីសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមសំខាន់ៗភាគច្រើន នៅតែអាចយកមកអនុវត្តបានរហូតដល់សព្វថ្ងៃ ។ ច្បាប់ទាំងនោះ យោងទៅលើឯកសារច្បាប់មនុស្សធម៌អន្តរជាតិចំនួនបួន រួមមាន "អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩" និង ពិធីសារចំនួនពីរផ្សេងទៀតនៃអនុសញ្ញាឆ្នាំ១៩៧៧ ។ "ការរំលោភបំពានធ្ងន់ធ្ងរ" ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាឧក្រិដ្ឋកម្មសង្គ្រាម ។ ឧក្រិដ្ឋកម្មសង្គ្រាម ក៏អាចបង្កើតឡើង ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាក់អន្តរជាតិសាធារណទូទៅ ឬអាចបង្កើតឡើងតាមរយៈអនុសញ្ញា ឬសន្ធិសញ្ញាផ្សេងៗ ។

ជាសរុប យើងអាចនិយាយបានថា ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម សំដៅទៅលើទង្វើទាំងឡាយណាដែលប្រព្រឹត្តិឡើងក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ហើយទង្វើទាំងនោះបានរំលោភបំពានទៅលើច្បាប់ ដែលពាក់ព័ន្ធទៅនឹងការការពារជនទាំងឡាយ ដែលមិនបានចូលរួមក្នុងការធ្វើសង្គ្រាម ដូចជាប្រជាជនស៊ីវិល ទាហានដែលរងរបួស និងជនឈ្លើយសឹក ព្រមទាំងក្រុមដែលទទួលបានការការពារ ។

## តើច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមអាចអនុវត្តបាននៅពេលណា?

ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម អាចអនុវត្តបាននៅពេលដែលមានជម្លោះប្រដាប់អាវុធកើតឡើង ។ ជាមួយគ្នានេះដែរ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួនអាចអនុវត្តបាន ចំពោះតែជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ ។ នេះមានន័យថា ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម មិនអាចអនុវត្តចំពោះ ជម្លោះប្រដាប់អាវុធមួយចំនួនដូចជា សង្គ្រាមស៊ីវិល ដែលភាគីជម្លោះជាក្រុមដែលរស់នៅក្នុងប្រទេសតែមួយ ។ លើសពីនេះទៅទៀត គ្រប់ឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់ ត្រូវតែមានការប្រើប្រាស់អាវុធ ។ នេះមានន័យថា បទល្មើសទាំងឡាយណាដែលកើតមានឡើងនៅក្នុងអំឡុងពេលសង្គ្រាម តែមិនមានពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ បទល្មើសនោះមិនត្រូវបានចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមនោះទេ ។ ជាឧទាហរណ៍ ប្រសិនបើមានជនណាម្នាក់សម្លាប់ប្រជាជនស៊ីវិល ព្រោះតែហេតុផលផ្ទាល់ខ្លួន បទល្មើសនោះមិនត្រូវបានចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមនោះឡើយ បើទោះបើជា បទល្មើសនោះកើតឡើងក្នុងអំឡុងពេលសង្គ្រាមក៏ដោយ ។

ដូចដែលបានរៀបរាប់ខាងលើ ឧក្រិដ្ឋកម្មសង្គ្រាមកើតឡើងប្រឆាំងនឹង ក្រុមមនុស្សដែលទទួលបានការការពារ ពោលគឺអ្នកដែលមិនបានចូលរួមនៅក្នុងសង្គ្រាម ដូចជា ប្រជាជនស៊ីវិល អ្នកធ្វើការផ្នែកសប្បុរសធម៌ ទាហានដែលរងរបួសមិនអាចចូលរួមប្រយុទ្ធបាន និងជនឈ្លើយសឹក ។ ដោយសារតែច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមភាគច្រើន ត្រូវបានបង្កើតឡើងនៅខណៈពេលដែលមានសង្គ្រាមរវាងប្រទេសមួយ និងប្រទេសមួយទៀត ហើយកងកម្លាំងបរទេសបានធ្វើការរំលោភបំពានដល់ប្រជាជនស៊ីវិលនៃប្រទេសដទៃក្នុងអំឡុងនៃសង្គ្រាម ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួន ត្រូវបានស្រង់ចេញពីអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់អនុវត្តចំពោះប្រជាជនស៊ីវិលនៃប្រទេសមួយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ជនបរទេស ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវបានយកមកប្រើប្រាស់សម្រាប់ការពារជនស៊ីវិលទាំងឡាយណា ដែលត្រូវបានធ្វើទុក្ខបុកម្នេញដោយរដ្ឋាភិបាលរបស់ខ្លួន នៅក្នុងអំឡុងពេលមានសង្គ្រាមឡើយ ។

## ឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការអត់ឃ្លាន

ដោយផ្អែកលើច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមថ្មី ឧក្រិដ្ឋកម្មសង្គ្រាម គឺជាឧក្រិដ្ឋកម្មមួយដែលបាន "ប្រើប្រាស់ការបង្អត់អាហារប្រជាជនស៊ីវិលដោយចេតនា ជាមធ្យោបាយក្នុងការធ្វើសង្គ្រាម ។ ការបង្អត់អាហារនេះធ្វើឡើងក្នុងគោលបំណងមិនឲ្យប្រជាជនស៊ីវិលអាចមានលទ្ធភាពរស់បាន រួមមាន ការ

បន្ទាក់ការផ្តល់ជំនួយមនុស្សធម៌ ដូចដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ» ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ឧក្រិដ្ឋកម្មនេះ ត្រូវបានដកស្រង់ចេញពី ពិធីសារមួយក្នុងចំណោមពិធីសារឆ្នាំ១៩៧៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ត្រូវបានប្រើប្រាស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ឧក្រិដ្ឋកម្មនេះ បានលើកឡើងពីការប៉ុនប៉ងកាត់ផ្តាច់ជំនួយស្បៀងអាហារទៅដល់ប្រជាជនស៊ីវិលរបស់គូជម្លោះ និងការរារាំងដល់ការផ្តល់ជំនួយរបស់អន្តរជាតិ ពីសំណាក់កងយោធា នៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ។ ផ្ទុយទៅវិញឧក្រិដ្ឋកម្មសង្គ្រាម មិនអាចចោទប្រកាន់បានចំពោះទង្វើរបស់រដ្ឋាភិបាលមួយ ដែលបង្កឲ្យប្រជាជនស៊ីវិលខ្លួនឯងជួបប្រទះគ្រោះអត់ឃ្លាននោះទេ ។

វាជាការរំលោភបំពានមួយ ទៅលើបទដ្ឋាននៃការទទួលបានការកាត់ទោសដោយស្មើភាពគ្នាចំពោះមុខច្បាប់ ប្រសិនបើតុលាការមួយកាត់ទោសជនល្មើសណាម្នាក់ ពីបទឧក្រិដ្ឋមួយដែលបានកើតឡើងមុនពេលច្បាប់សម្រាប់កាត់ទោសបទឧក្រិដ្ឋនោះមិនទាន់បានបង្កើត ។ ដូច្នេះ នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានតែបទឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួនប៉ុណ្ណោះត្រូវបានលើកឡើង ។ ជាងនេះទៅទៀត បទឧក្រិដ្ឋកម្មសង្គ្រាមទាំងនោះ ត្រូវបានស្គាល់ថា ជាការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ បទល្មើសនៃការប្រើប្រាស់ការបង្អត់អាហារជាមធ្យោបាយមួយក្នុងការធ្វើសង្គ្រាម មិនបានលើកឡើងនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែ ឧក្រិដ្ឋមួយចំនួនផ្សេងទៀត ដែលបានលើកឡើងនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានការពាក់ព័ន្ធទៅនឹងការអត់ឃ្លាន និងគ្រោះទុរភិក្សដែរ ។ ចំពោះឧក្រិដ្ឋកម្មចំនួនផ្សេងទៀត ដែលមានរៀបរាប់ដូចខាងក្រោម បើយើងក្រឡេកមើលមួយភ្លែត ហាក់ដូចជាមានការពាក់ព័ន្ធនឹងការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហមៈ

- ការសម្លាប់ដោយចេតនា
- ការធ្វើទារុណ្ណកម្ម ឬការធ្វើទុក្ខបុកម្នេញ
- ការបង្កឲ្យមានការឈឺចាប់ ឬរបួសធ្ងន់ធ្ងរទៅលើរូបកាយ ឬសុខភាព ដោយចេតនា
- និង ការនិរទេស ឬផ្លាស់ប្តូរកន្លែងរស់នៅ ឬការឃុំឃាំងប្រជាជនស៊ីវិល ដោយខុសច្បាប់ ។

ជាទូទៅ ប្រសិនសិនបើមានការដាក់បង្ខំនូវលក្ខខណ្ឌរស់នៅចំពោះប្រជាជនស៊ីវិល ឬក្រុមដែលទទួលបានការការពារ ឲ្យរស់នៅក្នុងភាពអត់ឃ្លានដោយចេតនា ក្នុងគោលបំណងបង្កឲ្យជនទាំងនោះស្លាប់ទង្វើនោះអាចចោទប្រកាន់ថាជា ការសម្លាប់ដោយចេតនា ។ ស្រដៀងគ្នានឹងនេះដែរ ប្រសិនបើជនស៊ីវិល ឬក្រុមដែលទទួលបានការការពារ ទទួលរងការធ្វើទុក្ខបុកម្នេញដោយចេតនា តាមរយៈការមិន

ផ្តល់ចំណីអាហារ ឧទាហរណ៍ ការធ្វើទារុណ្ណកម្មទៅលើឈ្លើយសឹកដោយការឃុំឃាំង និងមិនផ្តល់អាហារ ទង្វើនោះអាចចោទប្រកាន់ថាជា ការធ្វើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញ ។ ចំណែកឯ និយមន័យនៃការបង្កឲ្យមានការឈឺចាប់ ឬរបួសដោយចេតនា ហាក់ដូចជាពុំមានលក្ខណៈច្បាស់លាស់នោះទេ ។ ប៉ុន្តែ យើងអាចយកមកប្រើប្រាស់បាន ដោយផ្តោតទៅលើស្ថានភាពមួយដែល ការផ្តល់អាហារដល់ក្រុមដែលទទួលបានការការពារត្រូវបានកាត់បន្ថយដោយចេតនា ឬក្រុមនោះត្រូវបានដាក់ឲ្យរស់នៅក្នុងស្ថានភាពទុរភិក្ខ ក្នុងគោលបំណងបង្កឲ្យមានការឈឺចាប់ ។ លើសពីនេះទៅទៀត ស្ថានភាពនៃការអត់ឃ្លានអាចមានកើតឡើង ឬកាន់តែអាក្រក់ឡើង នៅពេលដែលប្រជាជនរងគ្រោះត្រូវបានក្រុមប្រដាប់អាវុធរារាំងមិនឲ្យផ្លាស់ទីដោយសេរី ទៅតំបន់ណា ដែលសម្បូរផលិតផលស្បៀងអាហារ ឬតំបន់ដែលមានការចែកចាយអាហារ ដូចជា ជំរុំជនភៀសខ្លួន ជាដើម ។

ឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ ពុំមានបទឧក្រិដ្ឋណាមួយដែលសក្តិសម ដើម្បីធ្វើការចោទប្រកាន់ចំពោះការអត់អត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ។

ជាក់ស្តែង ជនរងគ្រោះដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម មិនមែនជាក្រុមដែលទទួលបានការការពារ ក្រោមច្បាប់នៃអនុសញ្ញាទីក្រុងហ្សឺណែវនោះទេ ។ មិនតែប៉ុណ្ណោះ ការអត់ឃ្លានដែលបានកើតឡើងនៅពេលនោះ មិនមានការពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមនោះទេ ដោយសារតែៈ

ទី១ៈ ខ្មែរក្រហមដែលឡើងមកកាន់អំណាចនៅប្រទេសកម្ពុជា មិនមែនជាជនបរទេសនោះទេ ។ ប៉ុន្តែ ខ្មែរក្រហម ជារដ្ឋាភិបាលផ្លូវការរបស់កម្ពុជា ។ នេះមានន័យថា ជនរងគ្រោះដោយការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម មិនមែនជាក្រុមនៃជនដែលទទួលបានការការពារនោះទេ ។

ទី២ៈ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានទទួលស្គាល់ថា នៅក្នុងរបបខ្មែរក្រហម ភាពតានតឹង និងការប្រយុទ្ធគ្នាតាមបណ្តោយព្រំដែនខ្មែរ-វៀតណាម ពិតជាបានកើតឡើងមែន ហើយជម្លោះនេះ ត្រូវបានតុលាការទទួលស្គាល់ថាជា ជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលអាចចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាម ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អាចចោទប្រកាន់ឧក្រិដ្ឋកម្មនេះ ពីបទរំលោភបំពានដ៏ធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មសង្គ្រាម ។ ប៉ុន្តែយើងមិនអាចបង្ហាញថាបទចោទប្រកាន់នីមួយៗមានការពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមនោះទេ ។ការអត់ឃ្លានក្នុងរបបខ្មែរក្រហមហាក់ដូចជាមិនមានការពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធនោះទេ ដោយសារតែ ការអត់ឃ្លាន ដែលបានកើតឡើងនោះ បានបង្កឡើងដោយគោលនយោបាយរបស់រដ្ឋាភិបាលខ្មែរក្រហម ។ ជាងនេះទៅទៀត ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម មិនបានធ្វើឲ្យទិន្នផលដំណាំរបស់កម្ពុជាធ្លាក់ចុះ

នោះទេ។ ជាក់ស្តែង ភូមិភាគដែលរងគ្រោះដោយសារការអត់ឃ្លានខ្លាំងជាងគេ នៅក្នុងរបបខ្មែរក្រហម គឺភូមិភាគពាយព្យ និងតំបន់មួយចំនួនទៀត ដែលនៅឆ្ងាយពីតំបន់ដែលមានជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម។ នេះសបញ្ជាក់ឲ្យឃើញថា ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម មិនបានបង្កឲ្យមានកង្វះខាតស្បៀងអាហារសម្រាប់ប្រជាជនស៊ីវិលនោះទេ។

ជាសរុប ការអត់ឃ្លាន តែងតែកើតមានឡើងស្របពេលនឹងជម្លោះប្រដាប់អាវុធ និងសង្គ្រាម។ ជាច្រើនសតវត្សរ៍កន្លងមកហើយ ច្បាប់មនុស្សធម៌បានបញ្ចូលចំណុចជាច្រើន ដើម្បីកាត់បន្ថយការបំផ្លាញចំពោះជនដែលមិនបានចូលរួមនៅក្នុងសង្គ្រាម ដែលក្នុងនោះរួមមាន ការដាក់ទោសចំពោះការប្រើប្រាស់ការបង្អត់អាហារជាយុទ្ធសាស្ត្រមួយក្នុងការធ្វើសង្គ្រាម។ ជាក់ស្តែង គ្រោះអត់ឃ្លានដែលបានកើតឡើងនៅ តំបន់ដាហ្វ៊័រ (Darfur) នៃប្រទេសស៊ូដង់ (Sudan) ឬប្រទេសសូម៉ាលី (Somalia) អាចចាត់ជាឧក្រិដ្ឋកម្មសង្គ្រាមបាន ដោយយោងទៅតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ការរំលោភបំពានធ្ងន់ធ្ងរចំពោះច្បាប់មនុស្សធម៌ អាចមានការពិបាកក្នុងការបង្ហាញថាជាឧក្រិដ្ឋកម្មសង្គ្រាម បើយោងតាមបរិបទនៃការអត់ឃ្លានសម័យបច្ចុប្បន្ន។ ថ្វីបើមានការពិបាកក្នុងការបង្ហាញ ឧក្រិដ្ឋកម្មសង្គ្រាម នៅតែបន្តជាប់ទាក់ទងទៅនឹងករណីនៃការអត់ឃ្លានដដែល ឧទាហរណ៍ដូចជា ការដកហូតស្បៀងអាហាររបស់ប្រជាជនស៊ីវិល ដោយប្រើកងយោធា ការបំផ្លាញផលិតកម្មស្បៀងអាហារ ឬការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធទទួលបានអាហាររបស់ជនស៊ីវិល នៅក្នុងទឹកដីដែលខ្លួនគ្រប់គ្រង។ បទឧក្រិដ្ឋកម្មសង្គ្រាមដែលបានរៀបរាប់ទាំងនេះ មិនបានឆ្លុះបញ្ចាំងពីការអត់ឃ្លាន ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ហើយការអត់ឃ្លានដែលបានកើតឡើងនោះមិនមានការជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមនោះទេ។ ផ្ទុយទៅវិញវាគឺជាលទ្ធផលដែលកើតចេញពីគោលនយោបាយរបស់ខ្មែរក្រហម។ លើសពីនេះទៅទៀត ដូចដែលយើងបានពិភាក្សាក្នុងវគ្គទី៥រួចមកហើយ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទំនងជាអាចយកមកអនុវត្តបាន ចំពោះករណីដែលរដ្ឋាភិបាលមួយធ្វើការរំលោភបំពានទៅលើប្រជាជនខ្លួនឯង។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ឧក្រិដ្ឋកម្មសង្គ្រាមដែលមានការទាក់ទងទៅនឹងការអត់ឃ្លាន ដែលជាលទ្ធផលនៃជម្លោះប្រដាប់អាវុធ មិនអាចយកមកចោទប្រកាន់ចំពោះការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហមនោះទេ។

*(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកអត្ថបទមួយក្រោមចំណងជើងថា "ជីវិតគ្រួសារខ្ញុំក្នុងរបបខ្មែរក្រហម" ចេញផ្សាយដោយទស្សនាវដ្តី "ស្វែងរកការពិត" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១២៦ ខែមិថុនា ឆ្នាំ២០១០ សរសេរដោយ ញ៉ិល សល្យ ។)*

# ជីវិតគ្រួសារខ្ញុំក្នុងរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ ញ៉ិល សល្យ កើតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ នៅភូមិរកា ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។ ឪពុករបស់ខ្ញុំឈ្មោះ ហែល ញ៉ិល បច្ចុប្បន្នរស់នៅស្រុកពារាំង ខេត្តព្រៃវែង ។ ម្តាយរបស់ខ្ញុំឈ្មោះ សុខ ភ្ញាញ ស្លាប់នៅឆ្នាំ ១៩៩៣ដោយសារជំងឺ ។ ខ្ញុំមានបងប្អូនបង្កើតចំនួនប្រាំពីរនាក់ (ប្រុស៥នាក់ និងស្រី២នាក់) ។

កាលពីឆ្នាំ១៩៧៥ ពេលដែលឪពុកម្តាយរបស់ខ្ញុំជាអាជីវករលក់ដូរនៅផ្សារស្វាយពល ក្នុងភូមិស្វាយពល ខេត្តព្រៃវែង គាត់ត្រូវរត់គេចខ្លួនជាញឹកញាប់ដោយសារការទម្លាក់គ្រាប់បែករបស់កងទ័ពអាមេរិកាំងដើម្បីកម្ទេចជំរំចលនាដែលប្រឆាំងនឹងរដ្ឋាភិបាលលោកសេនាប្រមុខ លន់ នល់ ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលកងទ័ពខ្មែរក្រហមបានចូលមកកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង គ្រួសាររបស់ខ្ញុំមិនទាន់ត្រូវបានជម្លៀសចេញពីភូមិទេ ។ លុះដល់ឆ្នាំ១៩៧៦ ទើបគ្រួសាររបស់ខ្ញុំក៏ដូចជាគ្រួសារដទៃទៀតត្រូវបានជម្លៀសទៅភូមិរកា ដែលមានចម្ងាយប្រហែលបីគីឡូម៉ែត្រពីភូមិស្វាយពល ។

នៅទីនោះ ខ្មែរក្រហមបានប្រគល់ផ្ទះគំរូពីរខ្នងដែលបានសង់ទុកសម្រាប់ប្រជាជនថ្មីដែលទើបជម្លៀសមកពីទីក្រុងឲ្យស្នាក់នៅសិន ដោយមួយគ្រួសារទទួលបានផ្ទះមួយខ្នង ។ បន្ទាប់មក គ្រួសាររបស់ខ្ញុំត្រូវបានអង្គការបំបែកឲ្យទៅធ្វើការនិងរស់នៅតំបន់ឆ្ងាយៗពីគ្នា ។ ខ្មែរក្រហមបានបញ្ជូនឪពុករបស់ខ្ញុំទៅធ្វើការនៅវាលស្រែដែលមានចម្ងាយប្រហែល២០ម៉ែត្រពីកន្លែងរស់នៅ ដោយត្រូវធ្វើការចាប់ពីព្រលឹមរហូត ដល់ល្ងាចនិងទទួលរបបអាហារបន្តិចបន្តួចប៉ុណ្ណោះ ។ ដោយភាពស្រេកឃ្លានខ្លាំងពេក ឪពុករបស់ខ្ញុំបានដើរលួចចាប់ក្តាមនិងកូនក្អុកយកមកស្ងោរហូបបន្ថែមទៀត ។ តែជាអកុសល ឪពុករបស់ខ្ញុំស្រាប់តែត្រូវកងសន្តិសុខខ្មែរក្រហមចាប់បាន រួចនាំគាត់ទៅអប់រំរយៈពេលបីយប់បួនថ្ងៃទើបដោះលែងឲ្យមានសេរីភាពវិញ ។ ចាប់ពីពេលនោះមក ឪពុករបស់ខ្ញុំលែងហ៊ានលួចរបស់របរអង្គការទៀតហើយ ដោយសុខចិត្តធ្វើការទាំងហេវហត់ ។



ញ៉ិល សល្យ អំឡុងពេលចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចំណែកម្តាយរបស់ខ្ញុំវិញ បន្ទាប់ពីខ្មែរក្រហមជម្លៀសទៅដល់ភូមិរកា គាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើជាប្រធានរោងបាយក្នុងសហករណ៍៤ ដែលជាកន្លែងរស់នៅថ្មី ។ នៅទីនេះ ម្តាយរបស់ខ្ញុំក៏ធ្វើការចាប់ពីព្រលឹមដល់ព្រលប់ទើបត្រឡប់មកកងដូចឪពុករបស់ខ្ញុំដែរ ។ ប៉ុន្តែគាត់មិនសូវទទួលរងការងាររលំបាកប៉ុន្មានទេ ដោយសារតែឪពុកមាបង្កើតរបស់គាត់មានតួនាទីជាប្រធានឃុំនៅទីនោះ ។ ចំណែករបបអាហារវិញ ម្តាយ

របស់ខ្ញុំទទួលបានរបបហូបចុកគ្រប់គ្រាន់ ។

បងស្រី និងបងប្រុសរបស់ខ្ញុំដែលមានអាយុពេញវ័យ ត្រូវចាត់តាំងឲ្យចូលរួមក្នុងកងចល័ត លើកទំនប់ទន្លេតូចដែលស្ថិតនៅក្នុងភូមិព្រែកចំប៉ា ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង ចម្ងាយប្រហែល១៥គីឡូម៉ែត្រពីកន្លែងស្នាក់នៅ ។ នៅទីនោះ គាត់ទាំងពីរនាក់ត្រូវបានបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរបំផុត ដូចជាលីសែង កាប់គាស់តាំងពីព្រឹក រហូតដល់កណ្តាលអធ្រាត្រ រហូតដល់ធ្លាក់ខ្លួនឈឺ ។ ចំណែកអាហារវិញ មិនដែលហូបគ្រប់គ្រាន់ទេ ។ ដូច្នេះហើយ ក្រោយពីសម្រាកការងារ គាត់ទាំងពីរនាក់តែងតែទៅលួចគាស់ដំឡូងហូបជានិច្ច រួចយកមើមដំឡូងខ្លះមកចងវេចនឹងក្រមាដើរសំដៅមកផ្ទះ ។ ថ្ងៃមួយ ខ្មែរក្រហមបានមកទាន់ រួចវាយគាត់ទាំងពីរយ៉ាងដំណំ ហើយបញ្ជូនទៅដាក់នៅក្នុងមន្ទីរឃុំឃាំង រយៈពេល៥ថ្ងៃដើម្បីធ្វើការអប់រំ ។ នៅទីនោះ គាត់ត្រូវខ្មែរក្រហមធ្វើទារុណកម្មជាខ្លាំង ហើយថែមទាំងបង្អត់បាយទៀត ។ ដោយសារតែជាកំហុសលើកដំបូង អង្គការក៏ដោះលែងវិញ ប៉ុន្តែត្រូវបង្ខំឲ្យធ្វើការធ្ងន់ជាងមុន ដើម្បីជាការព្រមានដល់អ្នកផ្សេងទៀតកុំឲ្យយកគំរូតាម ។ ការងារទាំងនេះពិតជាពិបាកខ្លាំងណាស់ រហូតដល់បងស្រីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ធ្ងរ ។ ដោយសារតែព្រួយបារម្ភខ្លាំងពេក ម្តាយរបស់ខ្ញុំក៏បានសុំការអនុញ្ញាតមកមើលថែទាំកូន រហូតដល់ជាសះស្បើយពីជំងឺ ទើបត្រឡប់ទៅកងវិញ ។

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ គ្រួសាររបស់ខ្ញុំដែលមានឪពុកម្តាយ បងប្រុស និង បងស្រី ព្រមទាំងអ៊ំស្រីរបស់ខ្ញុំបានវិលត្រឡប់មករស់នៅភូមិស្នាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែងវិញ ។

ទោះបីក្រុមគ្រួសាររបស់ខ្ញុំមិនមាននរណាម្នាក់បាត់បង់ជីវិតក៏ដោយ តែរបបនេះពិតជាសាហាវ ព្រៃផ្សៃណាស់ ដោយបានសម្លាប់ប្រជាជនអស់ជិតពីរលាននាក់ ។ ដូច្នេះ ក្នុងនាមខ្ញុំជាអ្នកអប់រំប្រវត្តិសាស្ត្រម្នាក់ ខ្ញុំនឹងខិតខំធ្វើយ៉ាងណាអប់រំសិស្សានុសិស្ស និងនិស្សិតទាំងអស់ឲ្យយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ដោយឈរលើគោលការណ៍បង្រួបបង្រួមជាតិ ការផ្សះផ្សាជាតិ និងការអភិវឌ្ឍ ដើម្បីកសាងប្រទេសជាតិឲ្យមានការរីកចម្រើនដូចបណ្តាប្រទេសនានាលើពិភពលោក និងធ្វើយ៉ាងណាការពារទប់ស្កាត់មិនឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ។

ញិល សល្យ

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីវ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។

**សូមអរគុណ**

នេះជាចុងបញ្ចប់នៃវគ្គទី៦ នៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌកឯកសារកម្ពុជា ដែលនិយាយពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងការផ្សាយនៃវគ្គបន្ទាប់ យើងខ្ញុំនឹងពិភាក្សាការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមក្នុងបរិបទប្រវត្តិសាស្ត្រ ព្រមទាំងធ្វើការប្រៀបធៀបការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ជាមួយនឹងការអត់ឃ្លាននៅប្រទេសដទៃទៀត ដែលបានកើតឡើងនៅក្នុងសតវត្សរ៍ទី២០ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោថតសម្លេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗនៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើរមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ សូមអរគុណ ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។